# ពាក្យអធិដ្ឋានរបស់សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ
# នៅក្នុងព្រះបេះដូងដ៏និមលរបស់ព្រះនាងម៉ារី ជាក្សត្រីនៃសន្តិភាព

បពិត្រព្រះនាងម៉ារី! ដែលជាមាតារបស់ព្រះជាម្ចាស់ និងជាមាតារបស់យើងខ្ញុំ នៅក្នុងពេលវេលាដែលពិភពលោកកំពុងរងទុក្ខលំបាក យើងខ្ញុំសូមទូលអង្វរព្រះនាង។ ព្រះនាងម៉ារីបានស្រឡាញ់ និងស្គាល់យើងយ៉ាងច្បាស់លាស់ អ្វីៗទាំងអស់ដែលយើងមាននៅក្នុងដួងចិត្ត មិនមែនជាអាថិកំបាំងសម្រាប់ព្រះនាងឡើយ។ បពិត្រព្រះនាងម៉ារី ដែលមានព្រះហឫទ័យមេត្តាករុណា យើងខ្ញុំបានទទួលបទពិសោធន៍នៃការយកចិត្តទុកដាក់របស់ព្រះនាង និងវត្តមានរបស់ព្រះនាងបានណែនាំឱ្យយើងខ្ញុំមានសេចក្តីសុខសាន្តនៅក្នុងជីវិត។ ដូចពីដើម ព្រះនាងបានណែនាំឱ្យយើងខ្ញុំធ្វើដំណើរឆ្ពោះទៅព្រះយេស៊ូ ដែលជាព្រះអម្ចាស់នៃសន្តិភាព។

នៅពេលនេះ ពិភពលោករបស់យើងបានវង្វេងផ្លូវចេញពីមាគ៌ានៃសន្តិភាពហើយ យើងបានភ្លេចមេរៀននៃសោកនាដកម្មក្នុងប្រវត្តិសាស្ត្រប៉ុន្មានសតវត្សកន្លងមក ដែលជាការលះបង់នៃជីវិតមនុស្សរាប់លាននាក់ក្នុងសង្គ្រាមលោកលើកទី២។ យើងបានបដិសេធអំពីការប្តេជ្ញាចិត្តនិងសេចក្តីសម្រេចរួមរបស់សហគមន៍នៃពិភពលោក ដើម្បីកសាងសន្តិភាព។ យើងបានក្បត់សុបិននៃសន្តិភាព របស់ប្រជារាស្ត្រនានានៅលើពិភពលោក។ យើងបានក្បត់សេចក្តីសង្ឃឹមរបស់យុវជនយុវនារី យើងបានធ្លាក់នៅក្នុងជំងឺ គឺជំងឺនៃភាពលោភលន់។ យើងបានចូលនៅក្នុងជាតិនិយមហួសហេតុ យើងគិតតែពីផលប្រយោជន៍នៃជាតិសាសន៍របស់យើង ដែលណែនាំឱ្យយើងរីងស្ងួតដោយសារយើងលែងចាប់អារម្មណ៍អំពីបងប្អូនឯទៀតៗ។ យើងបានជ្រើសរើសផ្លូវមួយដែលណែនាំឱ្យយើងភ្លេចព្រះជាម្ចាស់ ដែលណែនាំឱ្យយើងរស់នៅក្នុងភាពកុហក ដែលណែនាំឱ្យយើងចេះតែចិញ្ចឹមអំពើហិង្សានៅក្នុងជីវិតរបស់យើង។ យើងបានសុខចិត្តបំផ្លាញជីវិត និងប្រមូលអាវុធយ៉ាងច្រើន ដោយភ្លេចតួនាទីរបស់យើង គឺជាអ្នកការពារ និងថែរក្សាបងប្អូនឯទៀតៗ និងថែរក្សាផ្ទះដែលជាពិភពលោកទាំងមូល។ យើងបានបំផ្លាញសួនច្បារនៃផែនដីដោយសារសង្គ្រាម

យើងបានណែនាំឱ្យព្រះហឫទ័យស្រឡាញ់របស់ព្រះជាម្ចាស់ឈឺចាប់ ដោយសារអំពើបាបរបស់យើង ដែលណែនាំឱ្យយើងទៅជាបងប្អូននឹងគ្នា។ ពិតមែន យើងបានក្លាយជាមនុស្សដែលលែងចាប់អារម្មណ៍អំពីបងប្អូនឯទៀតៗ និងអ្វីៗទាំងអស់ គឺចាប់អារម្មណ៍តែអំពីខ្លួនឯង។ ហេតុនេះហើយ ថ្ងៃនេះដោយទទួលអំពើបាបរបស់យើង ដោយការដាក់ខ្លួនយើងសុខចិត្តស្រែកថា "**ឱព្រះជាម្ចាស់អើយ សូមលើកលែងទោសឱ្យយើងខ្ញុំផង**"។

មាតានៃសន្តិភាពអើយ! នៅក្នុងទុក្ខលំបាកនៃអំពើបាបរបស់យើងខ្ញុំ នៅក្នុងការអស់កម្លាំងនិងភាពទន់ខ្សោយរបស់យើង នៅក្នុងអាថ៌កំបាំងនៃអំពើទុច្ចរិតដែលជាអំពើអាក្រក់និងសង្គ្រាម ព្រះនាងបានរំលឹកយើងខ្ញុំថា "**ព្រះជាម្ចាស់មិនដែលលះបង់ចោលយើង**"។ ព្រះជាម្ចាស់បន្តសំលឹងមើលយើងដោយព្រះហឫទ័យស្រឡាញ់ ព្រះជាម្ចាស់មានព្រះហឫទ័យតែមួយ គឺលើកលែងទោសឱ្យយើង ដើម្បីឱ្យយើងងើបឡើងវិញដើរឆ្ពោះទៅកាន់ជីវិតថ្មី។ ព្រះជាម្ចាស់បានប្រទានឱ្យយើងទាំងអស់គ្នាមានបេះដូងដ៏បរិសុទ្ធ ទៅជាទីពឹងរបស់ព្រះសហគមន៍និងរបស់មនុស្សជាតិនៅក្នុងពិភពលោក។ ព្រះជាម្ចាស់ដែលមានព្រះហឫទ័យស្រឡាញ់យើង បានគង់នៅជាមួយយើងនិងបន្តធ្វើដំណើរជាមួយយើងនៅក្នុងគ្រប់កាលៈទេសៈនៃប្រវត្តិសាស្ត្រ។

នៅពេលនេះ យើងខ្ញុំអធិដ្ឋានទូលអង្វរព្រះនាង និងគោះទ្វារនៃព្រះបេះដូងដ៏និមលរបស់ព្រះនាង។ យើងខ្ញុំដឹងថា យើងខ្ញុំទាំងអស់គ្នាជាកូនជាទីស្រឡាញ់របស់ព្រះនាង ដែលព្រះនាងបានសួរសុខទុក្ខយើងខ្ញុំពីដើមរៀងមក ដែលទូលអង្វរសម្រាប់យើងខ្ញុំ ដែលអញ្ជើញយើងខ្ញុំឱ្យកែប្រែចិត្តគំនិត។ នៅក្នុងពេលវេលាដ៏ងងឹតនេះ សូមព្រះនាងយាងមក ដើម្បីសង្គ្រោះយើងខ្ញុំ ដើម្បីលើកទឹកចិត្តយើងខ្ញុំ សូមជួយរំលឹកយើងខ្ញុំម្តងហើយម្តងទៀតថា "**ពិតមែនខ្ញុំគង់នៅជាមួយកូនៗ តើកូនៗចេះទទួលស្គាល់ព្រះមាតាឬទេ?**" ឱព្រះនាងម៉ារីអើយ! មានតែព្រះនាងទេដែលដឹងថាធ្វើដូចម្តេចដើម្បីស្រាយខ្សែដែលចងដួងចិត្តរបស់យើងខ្ញុំ នៅក្នុងប្រវត្តិសាស្ត្ររបស់យើងខ្ញុំ។ នៅពេលនេះ យើងខ្ញុំផ្ញើជីវិតទៅលើព្រះនាង ដោយដឹងថាយើងទុកចិត្តលើព្រះនាង យើងដឹងថាព្រះនាងទទួលនិងស្តាប់ពាក្យទូលអង្វររបស់យើង និងជួយយើង ដើម្បីឱ្យយើងទទួលសេចក្តីសង្ឃឹមនៅក្នុងពេលវេលាដ៏ពិបាកនេះ។

នេះហើយជាអ្វីដែលព្រះនាងបានធ្វើនៅក្នុងពិធីមង្គលការនៅភូមិកាណា ក្នុងស្រុកកាលីឡេ នៅពេលនោះព្រះនាងទូលអង្វរព្រះយេស៊ូ ហើយព្រះអង្គក៏បានធ្វើសញ្ញាសម្គាល់ដំបូងសម្រាប់ពិភព

លោក។ ដើម្បីរក្សាអំណរសប្បាយនៅក្នុងពិធីជប់លៀងនៃមង្គលការ នៅពេលនោះព្រះនាងបាននិយាយទៅព្រះយេស៊ូថា "**គេគ្មានស្រាទេ**" (យ៉ូហាន ២.៣)។ នៅពេលនេះ សូមព្រះនាងរំលឹកហើយរំលឹកទៀតទៅព្រះជាម្ចាស់ នៅពេលនេះដែលយើងកំពុងអស់កម្លាំង ដោយសារយើងអស់ស្រានៃសេចក្តីសង្ឃឹម អំណរសប្បាយបាត់បង់អស់ហើយ ភាតរភាពជាបងប្អូននៅក្នុងពិភពលោកបានបាត់បង់អស់ហើយ។ នៅពេលនេះយើងបោះបង់មនុស្សជាតិរបស់យើង នៅពេលនេះយើងបានបំផ្លាញអំណោយនៃសន្តិភាព។ យើងបើកដួងចិត្តរបស់យើងចំពោះអំពើហិង្សា និងបំផ្លិចបំផ្លាញអ្វីៗទាំងអស់ ដែលព្រះជាម្ចាស់បានកសាងនៅក្នុងព្រះហឫទ័យស្រឡាញ់របស់ព្រះអង្គ។ នៅពេលនេះ យើងខ្ញុំត្រូវការជំនួយពីព្រះនាង ដើម្បីចូលនៅក្នុងទុក្ខលំបាករបស់យើងខ្ញុំ ព្រះនាងជាម្តាយរបស់យើងខ្ញុំ។

ដូច្នេះ បពិត្រព្រះនាងម៉ារីដែលជាព្រះមាតាអើយ សូមស្តាប់ពាក្យអធិដ្ឋានរបស់យើងខ្ញុំ។
បពិត្រព្រះនាងម៉ារីដែលជាតារាសមុទ្រ សូមកុំឱ្យយើងខ្ញុំធ្លាក់នៅក្នុងទុក្ខលំបាកនៃសង្គ្រាម។
បពិត្រព្រះនាងម៉ារីដែលជាស្ពាននៃសម្ពន្ធមេត្រីថ្មី សូមជួយយើងឱ្យយើងមានគម្រោងការថ្មី ឱ្យយើងមានផ្លូវថ្មី ដើម្បីសម្រុះសម្រួលគ្នា ដើម្បីលើកលែងទោសឱ្យគ្នាទៅវិញទៅមក។
បពិត្រព្រះនាងម៉ារីដែលជាម្ចាស់ក្សត្រីនៃស្ថានបរមសុខ សូមណែនាំឱ្យសុខដុមរមនាដែលមកពីព្រះជាម្ចាស់ កើតឡើងសាជាថ្មីនៅក្នុងពិភពលោក។
សូមរំលត់អំពើហិង្សានិងភាពស្អប់ខ្ពើម សូមបំផ្លាញការសងសឹកគ្នា សូមបង្រៀនឱ្យយើងខ្ញុំចេះលើកលែងទោសឱ្យគ្នា។
សូមរំដោះយើងខ្ញុំចេញពីសង្គ្រាម សូមការពារពិភពលោកពីការគំរាមកំហែងនៃអាវុធនុយក្លេអ៊ែរ។
បពិត្រព្រះនាងម៉ារីដែលជាម្ចាស់ក្សត្រីនៃព្រះមាលា សូមណែនាំឱ្យយើងភ្ញាក់ស្មារតីដោយសារយើងត្រូវការអធិដ្ឋាន និងស្រឡាញ់ថែមទៀត។
បពិត្រព្រះនាងម៉ារីដែលជាព្រះមហាក្សត្រីនៃមហាគ្រួសារសម្រាប់ពិភពលោក សូមបង្ហាញផ្លូវដល់ប្រជារាស្ត្រនានាអំពីផ្លូវនៃភាតរភាព។
បពិត្រព្រះនាងម៉ារីដែលជាព្រះមហាក្សត្រីនៃសន្តិភាព សូមប្រទានសេចក្តីសុខសាន្តសម្រាប់ពិភពលោកទាំងមូល។

បពិត្រព្រះមាតាអើយ សូមឱ្យពាក្យអធិដ្ឋានដ៏និមលរបស់ព្រះនាងជំរុញបេះដូងរបស់យើងខ្ញុំដែលរឹងរូសចេះយំ។ សូមឱ្យទឹកភ្នែករបស់ព្រះនាង ដែលបានហូរស្រក់នៅក្បែរឈើឆ្កាង ជួយណែនាំ

ឱ្យផ្លូវជីវិតរបស់យើងអាចរស់ឡើងវិញនៅក្នុងសេចក្តីស្រឡាញ់។ បពិត្រព្រះនាងម៉ារី នៅពេលមានសំលេងនៃអាវុធ សូមឱ្យការអធិដ្ឋានរបស់ព្រះនាងជួយយើងខ្ញុំ សូមឱ្យដួងចិត្តរបស់យើងខ្ញុំពោរពេញដោយសេចក្តីសុខសាន្ត។ សូមព្រះនាង ធ្វើដំណើរជាមួយបងប្អូនដែលកំពុងរងទុក្ខលំបាក ដែលកំពុងភៀសខ្លួនដោយសារសង្គ្រាម។ សូមព្រះនាង ជួយលើកទឹកចិត្តបងប្អូនដែលត្រូវបង្ខំចិត្តភៀសខ្លួនចេញពីផ្ទះនិងទឹកដីកំណើតរបស់ពួកគេ។ សូមព្រះបេះដូងដ៏និមលរបស់ព្រះនាង ណែនាំឱ្យយើងខ្ញុំមានចិត្តអាណិតមេត្តា ដើម្បីឱ្យយើងខ្ញុំចេះបើកចិត្តគំនិត ដើម្បីទទួលស្វាគមន៍បងប្អូនដែលកំពុងរងទុក្ខលំបាក បងប្អូនដែលត្រូវគេបណ្តេញចេញដូចគ្មានតម្លៃ។

បពិត្រព្រះនាងម៉ារីដែលជាព្រះមាតារបស់ព្រះជាម្ចាស់ នៅពេលព្រះនាងនៅក្បែរឈើឆ្កាង ព្រះយេស៊ូទ្រង់ទតឃើញសាវ័កដែលនៅក្បែរព្រះនាង ហើយព្រះអង្គមានព្រះបន្ទូលថា "**អ្នកអើយ នេះហើយកូនរបស់អ្នក**" (*យ៉ូហាន ១៩,២៦*)។ នៅពេលនោះ តាមពិតព្រះយេស៊ូបានប្រគល់យើងម្នាក់ៗ នៅក្នុងសេចក្តីស្រឡាញ់របស់ព្រះនាង។ ក្រោយមក ព្រះយេស៊ូមានព្រះបន្ទូលទៅសាវ័ក និងយើងទាំងអស់គ្នាថា "**នេះហើយ ម្តាយរបស់អ្នក**" (*យ៉ូហាន ១៩,២៧*)។ បពិត្រព្រះនាងម៉ារី យើងខ្ញុំចង់ទទួលស្វាគមន៍ព្រះនាងម៉ារីនៅក្នុងជីវិតរបស់យើងខ្ញុំ និងនៅក្នុងប្រវត្តិសាស្ត្ររបស់យើងខ្ញុំ។ នៅពេលវេលានេះ ដែលមនុស្សលោកកំពុងអស់កម្លាំង និងកំពុងតក់ស្លុត បីដូចជាបានឈរនៅក្បែរឈើឆ្កាងរួមជាមួយព្រះនាង។ នៅពេលនេះ មនុស្សលោកត្រូវតែទូលអង្វរព្រះនាង ដើម្បីថ្វាយខ្លួនរបស់យើងខ្ញុំទៅព្រះយេស៊ូគ្រីស្តតាមរយៈព្រះនាង។ នៅពេលនេះ ប្រជារាស្ត្រនៅប្រទេសអ៊ុយក្រែន ក៏ដូចជាប្រជារាស្ត្រនៅប្រទេសរុស្ស៊ី ដែលស្រឡាញ់ព្រះនាងម៉ារីអស់ពីដួងចិត្តកំពុងទូលអង្វរព្រះនាង។ សូមឱ្យប្រជារាស្ត្រដែលកំពុងបាត់បង់ជីវិតដោយសារសង្គ្រាម ដោយសារការអត់ឃ្លាន ដោយសារភាពអយុត្តិធម៌ និងដោយសារភាពកំសត់ទុរគត អាចរកឃើញជីវិតថ្មីនៅក្នុងព្រះបេះដូងដ៏និមលរបស់ព្រះនាង។

ដូច្នេះហើយ សូមព្រះនាងម៉ារីដែលជាមាតារបស់ព្រះជាម្ចាស់ និងជាមាតារបស់យើងខ្ញុំ នៅពេលនេះយើងខ្ញុំអធិដ្ឋានថ្វាយយ៉ាងឱឡារិក នៅក្នុងព្រះបេះដូងដ៏និមលរបស់ព្រះនាង ទាំងយើងខ្ញុំផ្ទាល់ខ្លួន ទាំងព្រះសហគមន៍ ទាំងមនុស្សជាតិទាំងអស់ ជាពិសេសប្រទេសរុស្ស៊ីនិងប្រទេសអ៊ុយក្រែន។ សូមព្រះនាងម៉ារី ទទួលការថ្វាយខ្លួនរបស់យើងខ្ញុំ ដែលយើងខ្ញុំកំពុងធ្វើដោយការទុកចិត្ត និងសេចក្តីស្រឡាញ់។ សូមព្រះមាតា ណែនាំឱ្យសង្គ្រាមបញ្ឈប់ជាបន្ទាន់ ដើម្បីឱ្យមានសេចក្តីសុខសន្តនៅក្នុងពិភពលោកឆាប់ៗនេះ។ ពិតមែន អ្វីៗដែលផុសចេញពីព្រះបេះដូងដ៏និមលរបស់

ព្រះនាង បានបើកចំហរទ្វារនៃប្រវត្តិសាស្ត្រឱ្យបើកឡើង សម្រាប់ព្រះយេស៊ូដែលជាព្រះអង្គម្ចាស់នៃសន្តិភាព។ យើងខ្ញុំជឿជាក់ថា តាមរយៈព្រះបេះដូងដ៏និមលរបស់ព្រះនាង សន្តិភាពនឹងចាប់ផ្តើមលេចចេញជារូបរាងសាជាថ្មីម្តងទៀត។ យើងខ្ញុំសូមថ្វាយទៅព្រះនាងម៉ារី នូវអនាគតនៃមហាគ្រួសារនៅក្នុងពិភពលោកនេះ ទាំងសេចក្តីត្រូវការ ទាំងការទន្ទឹងរង់ចាំរបស់មនុស្សម្នាក់ៗនៅក្នុងពិភពលោក ទាំងទុក្ខលំបាក និងសេចក្តីសង្ឃឹមរបស់ពិភពលោក។

តាមរយៈការអង្វររបស់ព្រះនាងម៉ារី សូមព្រះហឫទ័យប្រណីសន្ដោសរបស់ព្រះជាម្ចាស់ ធ្លាក់ចុះមកលើផែនដីនេះដូចទឹកភ្លៀង ដើម្បីណែនាំឱ្យសេចក្តីសុខសាន្តដឹកនាំជីវិតរបស់យើងខ្ញុំពីមួយថ្ងៃទៅមួយថ្ងៃ។ បពិត្រព្រះនាងម៉ារី ដែលបានផ្ញើជីវិតទាំងស្រុងទៅលើព្រះជាម្ចាស់ ដែលបានទទួលព្រះវិញ្ញាណដ៏វិសុទ្ធដ៏ពេញលក្ខណៈ សូមណែនាំឱ្យពិភពលោករបស់យើងខ្ញុំ រស់នៅក្នុងសុខដុមរមនាដែលមកពីព្រះជាម្ចាស់ផ្ទាល់។ សូមប្រទានទឹកដ៏វិសុទ្ធ គឺទឹកដែលផ្តល់ជីវិតនៅក្នុងដួងចិត្តរបស់យើង ដោយដឹងថា "**ព្រះនាងជាប្រភពនៃសេចក្តីសង្ឃឹម**"។ បពិត្រព្រះនាងម៉ារី ដែលបានណែនាំឱ្យព្រះយេស៊ូចូលនៅក្នុងពិភពលោកដោយចាប់កំណើតជាមនុស្ស សូមព្រះនាងណែនាំឱ្យយើងខ្ញុំកសាងពិភពថ្មី ដែលចេះសហការគ្នា យល់ចិត្តគ្នា ជាអង្គតែមួយនៅក្នុងព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ។ បពិត្រព្រះនាងម៉ារី ព្រះនាងបានដើរនៅលើផ្លូវនៃពិភពលោករបស់យើងខ្ញុំ សូមជួយណែនាំឱ្យយើងខ្ញុំទាំងអស់គ្នា ដើរនៅលើផ្លូវនៃសេចក្តីសុខសាន្តផង។ អាម៉ែន៕

Copyright © Dicastero per la Comunicazione - Libreria Editrice Vaticana